**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការខេត្តកណ្តាល**
សំណុំរឿងព្រហ្មទណ្ឌ
លេខ ១២២ អក ចុះថ្ងៃទី ០៤
ខែ មេសា ឆ្នាំ ១៩៩៥

សាលក្រម
លេខ ៧៥ "ភ" ចុះថ្ងៃទី ២១
ខែ សីហា ឆ្នាំ ១៩៩៥

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការខេត្តកណ្តាល**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

បានបើកសវនាការជាសាធារណៈនៅតុលាការខេត្តកណ្តាល នៅថ្ងៃទី ២១ ខែ សីហា ឆ្នាំ ១៩៩៥ ដោយមាន :

**ចៅក្រមជំនុំជំរះ**

លោក [redacted] ប្រធានតុលាការខេត្តកណ្តាល

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការខេត្តកណ្តាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីតុលាការខេត្តកណ្តាល

**ដើម្បីជំនុំជំរះ**

១-ឈ្មោះ **ឆ ៩** អាយុ ៣៩ឆ្នាំ ជាតិខ្មែរ មុខរបររត់ម៉ូតូឌុប ទីលំនៅនៅភូមិដីឆ្នួង ឃុំស្អាងភ្នំ ស្រុកស្អាង ខេត្តកណ្តាល ឪពុកឈ្មោះ **ឧ ឡ** (ស) ម្តាយឈ្មោះ **ស ប** (ស) ប្រពន្ធឈ្មោះ **ឡ ស** មានកូន ០១នាក់ ទោសពីមុន *គ្មាន* ។

២-ឈ្មោះ **ស រ៩** អាយុ ២៧ឆ្នាំ មុខរបរលក់បាយ មានទីលំនៅនៅភូមិ សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ ។ ឪពុកឈ្មោះ **ស សគ** (ស) ម្តាយឈ្មោះ **ម ឃ** (ស) នៅលីវ ទោសពីមុន *គ្មាន* ។

៣-ឈ្មោះ **ម ឌ** អាយុ ៣៣ឆ្នាំ ជាតិខ្មែរ របររកស៊ីលក់ខោអាវ មានទីលំនៅសង្កាត់ផ្សារថ្មីទី ២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោះ **ឃ ម** (ស) ម្តាយឈ្មោះ **ឃ ស** (ស) ប្រពន្ធឈ្មោះ **ភ ឈរ** មានកូន ០២នាក់ ។

ត្រូវជាប់ចោទពីបទ : ចោរកម្ម ។

ប្រព្រឹត្តនៅភូមិព្រែកស្វាយ ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ១៩៩៥ ។

បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ឱ្យផ្តន្ទាទោសតាមមាត្រា ៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

តាមដីកាបញ្ជូនរឿងទៅជំនុំជំរះលេខ ១១០ ដជរ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៥ របស់ចៅក្រមស៊ើបសួរតុលាការខេត្តកណ្តាល និង របាយការណ៍ស្រាវជ្រាវ ចុះថ្ងៃទី០១

*សាលក្រមនេះចូលជាសាលក្រមស្ថាពរចាប់នៅថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៩៥ តទៅ ដោយគូភាគីពុំបានចូលមកប្តឹងតវ៉ា តាមកំណត់ច្បាប់ ។*

*កណ្តាល,ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៩៥*
**ក្រឡាបញ្ជី**
[redacted]

**បានឃើញ**
**ប្រធានតុលាការ**
[redacted]

ខែ មេសា ឆ្នាំ ១៩៩៥ របស់អធិការដ្ឋាននគរបាលស្រុកស្អាង ។

**នរពលសចនាគរ**

-ជនជាប់ចោទឈ្មោះ ម ធ បានឆ្លើយថា នៅថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ១៩៩៥ យើងខ្ញុំទាំងបីនាក់បាននាំគ្នាទៅស្អាងបំរុងទៅវត្តធនមន្ត ។ ហើយខ្ញុំបានយកដែកអក្សរអិល (L) តាំងពីផ្ទះខ្ញុំមកម្លេះ ហើយឈ្មោះ ស រដ និង ឈ្មោះ ត ៩ មិនដឹងខ្ញុំមានគោលបំណងទៅលួចម៉ូតូគេឡើយ ។ យើងខ្ញុំទាំងបីនាក់បានចេញដំណើរពីស្ពានជ្រោយចង្វា ។ លុះមកដល់ផ្សារតាខ្មៅ ខ្ញុំក៏ផ្តើមគំនិតបបួលទៅលួចម៉ូតូអ្នកទាំងពីរក៏អឺអើជាមួយគ្នា ។ យើងខ្ញុំទាំងអស់ក៏នាំគ្នាទៅ ទៅដល់ក៏នាំគ្នាឈប់ ។ ឈ្មោះ ស រដ ហៅ ម និងឈ្មោះ ៩ ក៏ចុះទៅងូតទឹកកន្លែងនោះ ខ្លួនបានឃើញម៉ូតូមួយគ្រឿង ទុកទៅក្បែរព្រែក ខ្លួនក៏យកដែកអក្សរអិលចាក់សោរបានហើយបំរុងចាក់សោកុងតាក់ទៀត គាប់ជួនម្ចាស់ម៉ូតូគេមកទាន់ក៏ នាំគ្នាបើកម៉ូតូខ្លួនឯងរត់តែម្តងរត់មិនរួច ដោយម្ចាស់ម៉ូតូគេជិះចេញតាមក្រោយ គេក៏ចាប់ខ្លួនបានតែម្តង ។ ពួកខ្លួនទាំង បីនាក់លួចម៉ូតូមិនបានឡើយ ។

-ជនជាប់ចោទឈ្មោះ ត ៩ បានឆ្លើយថា : នៅថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ១៩៩៥ យើងខ្ញុំទាំងបីនាក់បានធ្វើដំណើរពីស្ពានជ្រោយចង្វា គោលបំណងទៅលេងវត្តធនមន្ត ក្នុងស្រុកស្អាង ។ លុះមកដល់ផ្សារតាខ្មៅឈ្មោះ ម ធ ក៏បបួលរកលួចម៉ូតូតែចិត្តខ្ញុំមិនចង់ទៅឡើយ ដោយខ្លួនមិនស្គាល់ ម ធ ខ្លួនស្គាល់តែឈ្មោះ រដ ហើយ រដ គេព្រមទៅ ខ្លួនក៏ ទៅជាមួយតែម្តងទៅ ។ លុះទៅដល់ព្រែកតាកុង ខ្លួនឈប់ម៉ូតូចុះងូតទឹកពេលងូតទឹកនោះ គឺងូតជាមួយ ស រដ ឈ្មោះ ម ៩ អត់ងូតទឹកឡើយ ។ ពេលខ្លួនឡើងមកវិញក៏នាំគ្នាជិះម៉ូតូបានប្រហែលជា ៣គីឡូម៉ែត្រ ត្រូវនគរបាល ចាប់ខ្លួនតែម្តង ដោយគេចោទប្រកាន់ថា ពួកខ្លួនលួចឆ្នីះសោម៉ូតូគេ ដោយរូបខ្លួនមិនដឹងអ្វីឡើយ ។

-ជនជាប់ចោទឈ្មោះ ស រដ បានឆ្លើយថា : នៅថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ១៩៩៥ គ្នាខ្លួនមានគ្នា ០៣នាក់ បានជួបជុំគ្នានៅស្ពានជ្រោយចង្វា ចូលហូបកាហ្វេ ពេលហូបនោះឈ្មោះ ៩ បានបបួលខ្លួនទៅលេងវត្តធនមន្ត ខ្លួនក៏ព្រម ទៅ ។ បន្ទាប់ពួកខ្លួនមកដល់ផ្សារតាខ្មៅ ឈ្មោះ ម ធ បានបបួលខ្លួនទៅលួចម៉ូតូ ខ្លួនក៏ឯកភាពគ្នាទៅដោយជិះម៉ូតូមួយ គ្នាបីនាក់ សំដៅទៅស្អាង ។ លុះទៅដល់ព្រែកតាកុង ក៏នាំគ្នាឈប់ ខ្លួននឹងឈ្មោះ ៩ បានចុះងូតទឹកឈ្មោះ ម ធ អត់ងូត ទឹកទេនៅខាងលើ ពេលឈប់នោះ គឺឈប់នៅជិតម៉ូតូគេមួយគ្រឿងនៅជាប់ព្រែក ។ ខ្លួននឹងឈ្មោះ ៩ ចុះងូតទឹក ពេល ត្រឡប់មកវិញឈ្មោះ ម ធ ក៏ឱ្យខ្លួនអូសម៉ូតូ ខ្លួនក៏អូសម៉ូតូ ស្រាប់តែម្ចាស់គេឃើញគេស្រែក ខ្លួនក៏ទុកម៉ូតូរួចនាំគ្នា បើកម៉ូតូរត់ ក៏ត្រូវសមត្ថកិច្ចចាប់ខ្លួនតែម្តង ។

-តាមចម្លើយជនរងគ្រោះឈ្មោះ ខ ខ បានឆ្លើយថា : នៅថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ១៩៩៥ វេលាម៉ោង ០៤ល្ងាច ខ្លួនបានឌុបម៉ាស៊ីនបូមទឹកស្រោចត្រសក់ ហើយបានចតម៉ូតូទុកនៅត្រើយម្ខាងកំពុងតែបូមទឹកស្រោចនោះ ស្រាប់តែមានក្រុមចោរលួច ជិះម៉ូតូម៉ាកសាន់យ៉ាន ម៉ូតូមួយជិះគ្នាបីនាក់មកឈប់ម៉ូតូក្បែរម៉ូតូរបស់ខ្លួន អាម្នាក់រាង ខ្ពស់ និង អាម្នាក់ទៀតរាងទាបបន្តិច អង្គុយក្បែរម៉ូតូរបស់ខ្លួន ហើយអាម្នាក់ទៀតអង្គុយរាងឆ្ងាយពីម៉ូតូរបស់ខ្លួនបន្តិច ខ្លួនក៏ប្រើប្អូនថ្លៃឱ្យទៅមើលម៉ូតូ ពេលប្អូនខ្លួនរត់ទៅមើល ស្រាប់តែពួកវានាំគ្នាជិះម៉ូតូរត់ ខ្លួនក៏រត់មករកម៉ូតូស្រាប់ តែម៉ូតូដាច់សោករ ខ្លួនក៏បញ្ជោះម៉ូតូចេញតាមពីក្រោយរហូតដល់ប៉ូលីស១ក៏ចាប់បន្តពួកវាបាន ។ ក្នុងរឿងនេះខ្លួនសុំអោយ តុលាការផ្តន្ទាទោស តែមិនទាមទារជម្ងឺចិត្តឡើយ ។

-តាមចម្លើយអ្នកបំភ្លឺឈ្មោះ ស ខ បានឆ្លើយថា នៅថ្ងៃកើតហេតុខ្លួនកំពុងតែបាញ់ទឹកស្រោចដំណាំ ។ ស្រាប់តែពួកចោរជិះម៉ូតូមួយគ្រឿងមានគ្នាបីនាក់មកឈប់ជិតម៉ូតូរបស់បងថ្លៃខ្លួន ខ្លួនសង្ស័យថា ពួកវាបំរុងលួចម៉ូតូ ខ្លួន

ក៏រត់មកមើលម៉ូតូស្រាប់តែពួកវានាំគ្នាជិះម៉ូតូរត់ ពេលមកដល់កន្លែងម៉ូតូ ស្រាប់តែឃើញម៉ូតូដាច់សោករ ខ្លួនក៏រត់ទៅប្រាប់បងថ្លៃខ្លួន បងថ្លៃខ្លួនក៏ជិះម៉ូតូដេញតាម រហូតដល់ប៉ូលីសចាប់ខ្លួនបាន ។

-តាមចម្លើយសាក្សីបំភ្លឺ ឈ្មោះ ឌ ម បានឆ្លើយបំភ្លឺថា : ខ្លួនមិនដឹងរឿងលួចអ្វីឡើយ ស្រាប់តែឮសំរែកស្រែកថា ចាប់ចោរបានបីនាក់ ខ្លួនក៏ដើរទៅមើល ស្រាប់តែខ្លួនឃើញដែកអក្សរតេ "T" ជ្រុះនៅដី ខ្លួនក៏រើសដែកនោះឱ្យប៉ូលីសតែម្តង ហើយមុខចោរលួចខ្លួនមិនស្គាល់ ហើយក៏មិនដឹងថា ចោរលួចអ្វីដែរ ។

-តំណាងអយ្យការធ្វើការសន្និដ្ឋានថា ជនជាប់ចោទទាំង០៣នាក់នេះពិតជាមានបំណងទៅលួចម៉ូតូប្រាកដ ព្រោះឈ្មោះ ម ធ បានយកដែកអក្សរតេ "T" តាំងពីផ្ទះរបស់ខ្លួន ហើយមកដល់ផ្សារតាខ្មៅ ឈ្មោះ ស វ ក៏បានឆ្លើយថា ម ធ បានបបួលខ្លួន និង ឈ្មោះ ត ៩ ទៅរកម៉ូតូមួយគ្រឿង ហើយអ្នកទាំងពីរបានឯកភាពគ្នាទៅទាំងអស់គ្នា ។ ដូចនេះអ្នកទាំងបីនាក់ពិតជាមានបំណងទៅលួចម៉ូតូពិតប្រាកដ ហើយម្ចាស់ម៉ូតូថា ម៉ូតូរបស់ខ្លួនដាច់សោករនោះ ហើយម្ចាស់គេទាន់ កុំអីអ្នកទាំងបីនាក់យកម៉ូតូបាត់ហើយ ។ ដូចនេះតំណាងអយ្យការនៅតែរក្សាការចោទប្រកាន់របស់អយ្យការដដែល ។

-តំណាងអ្នកការពារក្តីបានសូមឱ្យលោកតុលាការ :

ក្រោយពីបានស្តាប់ចម្លើយរបស់កូនក្តីរបស់ខ្លួនឃើញថា កូនក្តីរបស់ខ្លួនមានគោលបំណងទៅលួចម៉ូតូ ហើយបានគាស់សោម៉ូតូរបស់ជនរងគ្រោះពិតប្រាកដ ដោយសារមានការយល់ដឹងតិច កិរិតជីវភាពក្រលំបាក ហើយតុលាការបានឃុំខ្លួនកូនក្តីរបស់ខ្លួនមានថេរៈវេលាសមគួរហើយ ដូចនេះសូមឱ្យតុលាការបន្ធូរបន្ថយទោស ឬ ក៏ដោះលែងកូនក្តីរបស់ខ្លួន ដោយកូនក្តីរបស់ខ្លួនរាងចាលហើយ ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយជនរងគ្រោះ

-ក្រោយពីបានស្តាប់ចម្លើយសាក្សី និង អ្នកបំភ្លឺ

-ក្រោយពីបានសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់អ្នកការពារ

-ក្រោយពីបានស្តាប់ចម្លើយចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការខេត្តកណ្តាល
## យល់ឃើញថា

-សេចក្តីចោទប្រកាន់របស់តំណាងអយ្យការមានសំអាងគ្រប់គ្រាន់តាមផ្លូវច្បាប់ ។

-សកម្មភាពជួបជុំគ្នា ពេលវេលា ដែលជនជាប់ចោទទាំងបីនាក់រួមដំណើរជាមួយគ្នា តាំងពីព្រលឹមរហូតដល់ពេលដែលស្ថាប័នមានសមត្ថកិច្ចចាប់ខ្លួនបាននៅវេលាម៉ោង ១៦ល្ងាច ការបោះចោលនូវពេលវេលាដែលខ្លួនត្រូវរត់ម៉ូតូឌុបសំរាប់ផ្គត់ផ្គង់ជីវភាពគ្រួសាររបស់ជនជាប់ចោទឈ្មោះ ត ៩ ការជួបជុំគ្នា ការពិភាក្សាគ្នា ការព្រមព្រៀងគ្នានៅផ្សារតាខ្មៅពីគំនិតទុច្ចរិត ។ អំពើគាស់សោម៉ូតូរបស់ជនជាប់ចោទឈ្មោះ ម ធ សកម្មភាព និង ល្បឿនក្នុងការបើកបរម៉ូតូរត់គេចខ្លួនរបស់ជនជាប់ចោទទាំងបីនាក់ នឹងការបំភ្លឺលើសកម្មភាពក្នុងការប្រព្រឹត្តបទល្មើសពីសំណាក់ជនរងគ្រោះ និងសាក្សីបានបញ្ជាក់អោយឃើញច្បាស់ថា ជនជាប់ចោទទាំងបីនាក់ពិតជាបានពិភាក្សា នឹងព្រមព្រៀងគ្នាក្នុងការប្រព្រឹត្តបទល្មើសជាមុន ។

-ចម្លើយរបស់ជនជាប់ចោទឈ្មោះ ម ឆ ដែលឆ្លើយសារភាពថា ខ្លួនជាអ្នកគាស់សោកុងតាក់ និង សោម៉ូតូរបស់ជនរងគ្រោះ ហើយជនទាំងពីរនាក់ពុំបានធ្វើសកម្មភាពដោយផ្ទាល់ជាចម្លើយដែលតុលាការអាចយកជាការបាន ដោយហេតុថា ការគាស់សោម៉ូតូអាចធ្វើឡើងដោយមនុស្សតែម្នាក់បាននិងម្យ៉ាងទៀតឧបករណ៍សំរាប់គាស់មានតែមួយប្រាកដមែន ។

-ទោះបីជាជនជាប់ចោទឈ្មោះ ស រដ និង ឈ្មោះ ភ ៩ បានឆ្លើយថា ខ្លួនពុំបានធ្វើសកម្មភាពដោយផ្ទាល់ និងឆ្លើយដោះសារថា ខ្លួនពុំដឹងពីសកម្មភាពរបស់ឈ្មោះ ម ឆ ។ ប៉ុន្តែសំអាងលើចម្លើយជនរងគ្រោះ សាក្សីបានបញ្ជាក់ឱ្យឃើញច្បាស់ថា ជនជាប់ចោទពីររូបបាននៅជិតជនដែលឈ្មោះ ម ឆ ហើយនៅក្បែរនឹងម៉ូតូរបស់ជនរងគ្រោះ ដូចនេះទោះបីជា ខ្លួនពុំចេញសកម្មភាពដោយផ្ទាល់ពិតមែន ប៉ុន្តែខ្លួនពិតជាបានដឹងបានឃើញនូវអំពើរបស់ឈ្មោះ ម ឆ ហើយនាំគ្នារត់គេច នៅពេលដែលដឹងថា ម្ចាស់ម៉ូតូបានដឹងពីសកម្មភាពរបស់បក្ខពួកខ្លួន ម្យ៉ាងទៀតផ្អែកលើចម្លើយរបស់ជនជាប់ចោទឈ្មោះ ស រដ ដែលបញ្ជាក់បានថា ពួកខ្លួនបានព្រមព្រៀងគ្នាដើរលួចម៉ូតូ មុនពេលមកដល់ទីកន្លែងប្រព្រឹត្តបទល្មើសទៀតផង ។ សកម្មភាពនេះបង្ហាញអោយឃើញនូវចេតនារួមគ្នាប្រព្រឹត្តបទល្មើសចោរកម្ម នឹងត្រូវបានច្បាប់ចាត់ទុកថា រួមគ្នាប្រព្រឹត្តបទល្មើស ។

-ចម្លើយចុងក្រោយរបស់ជនជាប់ចោទបានសារភាពវិញថា ខ្លួនពិតជាមានគំនិតព្រមព្រៀងគ្នាដើរលួចម៉ូតូបង្ហាញកាន់តែច្បាស់ថា អំពើរបស់ជនជាប់ចោទឈ្មោះ ម ឆ ពិតជាធ្វើឡើងដោយចេតនា ដោយមានការគាំទ្រពីសំណាក់ជនជាប់ចោទឈ្មោះ ភ៩ និង ស រដ ។

-មានសំអាងសាក្សីច្បាស់លាស់បញ្ជាក់បានថា ម៉ូតូរបស់ជនរងគ្រោះពិតជាត្រូវជនជាប់ចោទឈ្មោះ ម ឆ គាស់សោកុងតាក់ និង សោករប្រាកដមែន ។

-ការអាក់អានពុំបានទទួលផលដោយសារការប្រព្រឹត្តអំពើចោរកម្ម របស់ជនជាប់ចោទពុំមែនកើតឡើងដោយសារការបញ្ឈប់សកម្មភាពរបស់ជននេះឡើយ ។

-ជនជាប់ចោទទាំងបីនាក់ជាមនុស្សពេញវ័យ មានស្មារតីគ្រប់គ្រាន់យល់ នឹងអំពើ និង ត្រូវទទួលខុសត្រូវទាំងស្រុងលើរាល់សកម្មភាពរបស់ខ្លួន ។

-មានភស្តុតាង និង ពិរុទ្ធភាពគ្រប់គ្រាន់បញ្ជាក់ច្បាស់ថា ជនជាប់ចោទឈ្មោះ ស រដ ឈ្មោះ ម ឆ និង ឈ្មោះ ភ ៩ ពិតជាបានរួមគ្នាប្រព្រឹត្តអំពើចោរកម្មនៅចំណុចភូមិស្វាយការី ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ១៩៩៦ វេលាម៉ោងប្រហែល ០៤រសៀល ។

បទល្មើសដែលមានចែង និង បញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

មាត្រា ៤៣ បានចែងថា :

"ជនដែលលួច ឬ ប៉ុនប៉ងនឹងលួចដោយគ្មានទម្ងន់ទោស ព្រាងទុកក្នុងមាត្រា ៣៤ នូវទ្រព្យសម្បត្តិរបស់បុគ្គលត្រូវទទួលកំហុសបទល្មើសចោរកម្ម ហើយត្រូវផ្តន្ទាទោស យ៉ាំងពី ០៦ខែ ទៅ០៥ឆ្នាំ ។"

-សេចក្តីសន្និដ្ឋានរបស់អ្នកការពារលើចំណុចអវិជ្ជា ជីវភាព និង ការសារភាពរបស់ឈ្មោះ ម ឆ មានលក្ខណៈសមហេតុសមផលដែលតុលាការអាចលើកយកមកពិចារណាបាន ។

-ម៉ូតូរបស់ជនរងគ្រោះពុំបានបាត់បង់ឡើយ ហើយបច្ចុប្បន្នស្ថិតនៅក្រោមការកាន់កាប់របស់ជនរងគ្រោះ ហើយជនរងគ្រោះពុំមានទាមទារសំណងអ្វីឡើយ ដូចនេះតុលាការពុំលើកយកមកពិចារណាលើបញ្ហានេះឡើយ ។

តាមបញ្ញត្តិមាត្រា ៦៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

-មានសំអាងគ្រប់គ្រាន់បញ្ជាក់បានច្បាស់ថា ម៉ូតូដែលជនជាប់ចោទជិះជាកម្មសិទ្ធិរបស់ឈ្មោះ ស ទណ ហើយត្រូវបានជនជាប់ចោទខ្ចី ។ ម្យ៉ាងទៀតពុំមានសំអាងណាមួយបញ្ជាក់ថា ម្ចាស់ម៉ូតូបានដឹងពីគំនិតទុច្ចរិតរបស់ជនជាប់ចោទឡើយ ហើយម៉ូតូនេះត្រូវបានប្រគល់ឱ្យឈ្មោះ ស ទណ កាលពីថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ១៩៩៥ រួចហើយ ដូចនេះតុលាការពុំលើកយកមកសំរេចសេចក្តីឡើយ ។

-វត្ថុតាងមានដែកអក្សរតេ "T" លើប្រវែង ៨សង់ទីម៉ែត្រ ក្រោមប្រវែង ១០សង់ទីម៉ែត្រ មានជ្រុង០៦ ចំនួនមួយកំពុងរក្សាទុកនៅតុលាការ ។

-ជនជាប់ចោទត្រូវបានចាប់ខ្លួននៅថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ១៩៩៥ ។

## ហេតុដូច្នេះសំរេច :

១-ផ្តន្ទាទោស :

-ឈ្មោះ ម ឆ កំណត់ដាក់ពន្ធនាគារចំនួន ០៦ខែ គិតពីថ្ងៃចាប់ខ្លួនថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ១៩៩៥ ។

-ឈ្មោះ ភ ៩ កំណត់ដាក់ពន្ធនាគារចំនួន ០៦ខែ គិតពីថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ១៩៩៥ ។

-ឈ្មោះ ស វដ កំណត់ដាក់ពន្ធនាគារចំនួន ០៦ខែ គិតពីថ្ងៃចាប់ខ្លួនថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ១៩៩៥ ។

២-វត្ថុតាងមានដែករាងអក្សរតេ "T" ចំនួនមួយត្រូវរឹបអូស នឹងបំផ្លាញចោល ។

បទល្មើសនឹងការផ្តន្ទាទោសខាងលើ មានបញ្ញត្តិក្នុងមាត្រា ៤៣ នឹងមាត្រា ៦៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

៤-សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខ បើកផ្លូវប្តឹងឧទ្ធរណ៍រយៈពេល ០២ខែគិតពីថ្ងៃនេះតទៅ ។

**ចៅក្រមជំនុំជំរះ**

[redacted]

---

សេចក្តីនេះ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលក្រមស្ថាប័នមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ នឹងកងកំលាំងប្រដាប់អាវុធ ត្រូវជួយអនុវត្តសាលក្រមនេះឱ្យបានសំរេច បើមានសេចក្តីសុំត្រឹមត្រូវតាមច្បាប់ ។

*កណ្តាល, ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៩៥*

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ប្រធានតុលាការខេត្តកណ្តាល**

[redacted]